លោក **សែន វិចិត្រ** មានដើមកំណើតមកពីប្រទេសកម្ពុជា។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសិក្សាសន្តិភាពអន្តរជាតិពីសាកលវិទ្យាល័យដើម្បីសន្តិភាពរបស់អង្គការសហប្រជាជាតិនៅប្រទេសកូស្តារីកា សញ្ញាប័ត្រអនុបណ្ឌិតផ្នែកអប់រំពីសាកលវិទ្យាល័យស៊ីម៉ូនហ្វ្រេស៊ើរ ប្រទេសកាណាដា និងសញ្ញាបត្រក្រោយបរិញ្ញាផ្នែកភាសាវិទ្យាអនុវត្តពីមជ្ឈមណ្ឌលភាសាប្រចាំតំបន់នៅប្រទេសសិង្ហបុរី។ បច្ចុប្បន្នលោកកំពុងបញ្ចប់សញ្ញាបត្របណ្ឌិតផ្នែកអប់រំនៅសាកលវិទ្យាល័យប្រ៊ីតទីសកូឡុំប៊ៀ ប្រទេសកាណាដា។ លោកមានបទពិសោធជាច្រើនឆ្នាំក្នុងការបង្រៀននិស្សិតនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា។ លោកក៏មានបទពិសោធជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលជាវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាផងដែរ។ លោកមានចំណាប់អារម្មណ៍ស្រាវជ្រាវចម្បងលើប្រធានបទទាក់ទងទៅនឹងចលនភាពសង្គម អភិបាលកិច្ចវិស័យអប់រំ ទំនាក់ទំនងរវាងរដ្ឋនិងសាកលវិទ្យាល័យ ហិរញ្ញវត្ថុសង្គម និង ឯកជនភាវូបនីយកម្មនៅក្នុងវិស័យអប់រំ។

## ហេតុអ្វីបានជាយើងគួរតែចូលរួមប្រកបដោយវិចារណកិច្ចជាងនេះជាមួយនឹងផែនការអប់រំថ្មីរបស់ខេត្តប្រ៊ីតទីសកូឡុំប៊ៀរ?

ការចាប់ផ្តើមផែនការអប់រំថ្មីរបស់ខេត្តប្រ៊ីតទីសកូឡុំប៊ៀរបានទាក់ទាញទាំងក្តីរំភើប និង ការរិះគន់ពីសំណាក់អ្នកស្រាវជ្រាវ អ្នកអនុវត្ត និងសហគមន៍អប់រំនៅទូទាំងខេត្ត។ អ្វីដែលជាស្នូលនៃផែនការអប់រំថ្មីនេះគឺការរៀនសូត្រដោយផ្ទាល់ខ្លួនដែលអាស្រ័យលើបច្ចេកវិទ្យា។ ការផ្លាស់ប្តូរឆ្ពោះទៅរកគំរូនៃការរៀនថ្មីនេះមិនមែនជាបាតុភូតដាច់ដោយឡែកនោះទេ តែវាជាផ្នែកមួយនៃចលនាកំណែទម្រង់អប់រំតាមបែបសាជីវកម្មដ៏ទូលំទូលាយមួយ ដែលឈរលើផ្នត់គំនិតបែបសេរីនិយមថ្មីមួយ។ នៅក្នុងខេត្តប្រ៊ីតទីសកូឡុំប៊ៀ ការផ្លាស់ប្តូរគោលនយោបាយដ៏សំខាន់ទៅតាមរបត់គំនិតនេះបានចាប់ផ្តើមដោយការចេញក្រឹត្យវិសោធនកម្មសាលានៅឆ្នាំ ២០១២ (ដែលត្រូវគេស្គាល់ថាជាច្បាប់លេខ ៣៦)។ ការធ្វើវិសោធនកម្មនេះជំរុញឱ្យមានការគិត និងការអនុវត្តតាមបែបទីផ្សារនៅក្នុងការផ្តល់សេវាកម្ម និងការផ្តល់ថវិកាដល់កម្មវិធីអប់រំពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី១២។

ការវិភាគរបស់ខ្ញុំទៅលើផែនការអប់រំថ្មីនេះបានបង្ហាញថា ចក្ខុវិស័យសម្រាប់ការអប់រំនៅក្នុងខេត្តប្រ៊ីតទីសកូឡុំប៊ៀរត្រូវបានផ្លាស់ប្តូរងាកមកផ្តោតសំខាន់លើលទ្ធផលបែបសេដ្ឋកិច្ច។ ការផ្លាស់ប្តូរនេះនាំឱ្យមានការកំណត់ជាថ្មីនូវគោលបំណងនៃការអប់រំ ការអនុវត្តគរុកោសល្យ រួមទាំងតួនាទីរបស់គ្រូបង្រៀន សិស្ស និងឪពុកម្តាយរបស់សិស្ស។ ចក្ខុវិស័យថ្មីនេះអាចរួមចំណែកក្នុងការផ្លាស់ប្តូរការអប់រំសាធារណៈឱ្យទៅជាទីផ្សារ ដែលក្នុងនោះការអប់រំដើរតួនាទីជាចម្បងក្នុងការបម្រើតែប្រយោជន៍ឯកជនប៉ុណ្ណោះ។

ការរៀនសូត្រដោយផ្ទាល់ខ្លួនដែលអាស្រ័យលើបច្ចេកវិទ្យាជំរុញឱ្យមានលំនាំនៃការគិតនិងតក្កដែលផ្តោតជាចម្បងទៅលើការជ្រើសរើសនិងការប្រើប្រាស់ការអប់រំដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។ សាធារណជនទូទៅត្រូវបានគេតម្រង់ទិសទៅរកការត្រេះរិះ និង ការអនុវត្តដែលចាត់ទុកការអប់រំជាទំនិញប្រើប្រាស់ដែលអាចប្តូរតាមបំណងរបស់សិស្សម្នាក់ៗ។ អត្ថន័យនៃ "ការរៀន" ត្រូវបានកាត់បន្ថយនៅត្រឹមជាបញ្ជីជំនាញ ហើយសារៈសំខាន់នៃបរិបទវប្បធម៌សង្គមក្នុងការបង្រៀននិងការរៀនមិនត្រូវបានឱ្យតម្លៃទេ។ តួនាទីសំខាន់របស់គ្រូបង្រៀនត្រូវបានប្តូរពីអ្នកមានជំនាញវិជ្ជាជីវៈដែលមានចំណេះដឹង និងដែលជាប្រភពនៃតម្លៃសង្គមនិងសីលធម៌ មកត្រឹមតែជាគ្រូបង្វឹក ឬ អ្នកសម្របសម្រួលដំណើរការរៀនសូត្រប៉ុណ្ណោះ។ សិស្ស និង ឪពុកម្តាយរបស់ពួកគេគ្រាន់តែជាអ្នកប្រើប្រាស់ផលិតផលនិងសេវាកម្មអប់រំប៉ុណ្ណោះ ហើយភាពជាពលរដ្ឋ លទ្ធិប្រជាធិបតេយ្យ យុត្តិធម៌សង្គម និង សមធម៌មិនសូវត្រូវបានឱ្យតម្លៃនៅក្នុងផែនការអប់រំថ្មីនេះទេ។

ទោះបីមានមនុស្សមួយចំនួនអាចនឹងចូលចិត្តយុទ្ធវិធីអប់រំតាមបែបដោយឡែកៗនេះក៏ដោយ យើងទាំងអស់គ្នាត្រូវចាំថាការរៀនសូត្រគឺជាដំណើរការសង្គមដ៏ស្មុគស្មាញលើសពីការចាប់យកនូវមុខជំនាញ និងគុណលក្ខណៈដែលមានការវេចខ្ចប់រួចជាស្រេច ដែលសិស្សច្រើនបានឬត្រូវការប៉ុណ្ណោះទេ។ ហេតុនេះហើយ សំណួរសំខាន់ដែលយើងទាំងអស់គ្នាគួរតែគិតពិចារណានៅខណៈពេលនេះគឺ៖ តើយើងចង់ឱ្យអ្នកជំនាន់ក្រោយរបស់យើងរស់នៅក្នុងសង្គមបែបណានាពេលអនាគត? ក្នុងការគិតពិចារណាលើសំណួរនេះ បុគ្គលម្នាក់ៗ និងសហគមន៍ដែលពាក់ព័ន្ធទាំងអស់គួរតែចូលរួមប្រកបដោយវិចារណកិច្ចជាមួយនឹងផែនការអប់រំថ្មីនេះ។